អ៊ិនធើណេសិនណល ស្គូល អហ្វ សៀមរាប

# International School of Siem Reap

សេចក្តីជូនដំណឹង
សម្រាប់ខែមិថុនា ឆ្នាំ២០១៨
វុល:២
ផ្សព្វផ្សាយលើកទី:១០

# សេចក្តីជូនដំណឹងពីសាលាបឋមសិក្សា




## អំពីឆ្នាំសិក្សា ២០១៧-២០១៨

សូមជម្រាបជូនលោក-លោកស្រីដែលជាអាណាព្យាបាលទាំងអស់ជាទីគោរព,
ឆ្នាំសិក្សា២០១៧-២០១៨បានឈានចូលមកដល់ថ្ងៃបិទវគ្គក្នុងពេលដ៏ខ្លីខាងមុខនេះ ដែលជាលទ្ធផលឃើញថា សិស្សានុសិស្សទាំងអស់ជារួមមានកិច្ចខិតខំប្រឹងប្រែងចំពោះការសិក្សាបានយ៉ាងល្អ សិស្សទាំងអស់បានបង្ហាញអំពីការស្រលាញ់ការសិក្សាតាំងពីដើមឆ្នាំរហូតដល់ចុងឆ្នាំសិក្សា។ តាងនាងខ្ញុំដែលជានាយកប្រតិបត្តិភាសាអង់គ្លេសសូមថ្លែងអំណរគុណដល់គ្រូបង្រៀនទាំងអស់ ព្រមទាំងបុគ្គលិកគ្រប់ផ្នែកដែលបានចូលរួមជួយសហការក្នុងដំណើរការអប់រំនៃសាលាអន្តរជាតិ ISSRពេញមួយឆ្នាំ ដែលនាំឲ្យកិច្ចការអប់រំប្រកបទៅបានដោយរលូន។ ក្នុងឱកាសនៃការឈប់សម្រាកនាពេលខាងមុខនេះ នាងខ្ញុំសូមប្រសិទ្ធិពរជ័យដល់លោក-លោកស្រី ឬអាណាព្យាបាល ព្រមទាំងបុគ្គលិកគ្រប់ជាន់ថ្នាក់ឲ្យជួបតែសំណាងល្អគ្រប់ៗគ្នា។ នាងខ្ញុំ ព្រមទាំងបុគ្គលិកទាំងអស់នឹង បានជួបលោក-លោកស្រី សិស្សានុសិស្សទាំងអស់នៅសាលាបឋមសិក្សាអាគារថ្មីនៅថ្ងៃ**ចន្ទ** ទី**១៣** ខែ**សីហា** ឆ្នាំ២០១៨។

## អំពីអាគារថ្មីរបស់សាលាបឋម

ដំណើរការសាលាបឋមសិក្សាអាគារថ្មីកំពុងតែសាងសង់ជិតរួចរាល់ហើយ។ សម្រាប់ទីតាំងមកកាន់សាលាបឋមសិក្សាអាគារថ្មីគឺមាននៅក្នុងសេចក្តីជូនដំណឹងកាលពីខែមុន ទោះយ៉ាងណាសាលាកំពុងតែបង្កើតឲ្យមានការដៅចំណុចដាក់ទីតាំងក្នុងប្រពន្ធ័អ៊ិនធើណែត Google Map ដែលនឹងរួចរាល់ក្នុងពេលឆាប់ៗនេះ។












## អំពីកម្មវិធីសប្បុរសធម៌ដល់មន្ទីរពេទ្យកុមារអង្គរ និងមន្ទីរពេទ្យគន្ធបុប្ផា

នាងខ្ញុំពិតជាមានចិត្តសប្បាយរីករាយក្រៃលែងដល់លោក-លោកស្រីដែលបានចូលរួមជួយក្នុងដំណើរការសប្បុរសធម៌របស់សាលាអន្តរជាតិ ISSR ដូចជាកម្មវិធី School Fair, កម្មវិធីបុណ្យ Halloween កម្មវិធីលក់ទឹកក្រូច និងកម្មវិធីហែលទឹកប្រចាំឆ្នាំ ហើយជាសរុបយើងទទួលបានថវិការចំនួន ២៤៤0ដុល្លារអាមេរិច។ ថវិការដែលទទួលបានទាំងអស់គឺបានប្រគល់ជូនមន្ទីរពេទ្យទាំងពីរ ដោយក្រុមតំណាងសិស្ស ISSR





## អំពីលោកគ្រូអ្នកគ្រូនិងថ្នាក់រៀនឆ្នាំសិក្សា២០១៧-២០១៨

ក្នុងឆ្នាំសិក្សានីមួយៗតែងមានការចាកចេញពីសំណាក់លោកគ្រូអ្នកគ្រូក្រោយបញ្ចប់ការបង្រៀនរបស់ពួកគាត់ តែលោកគ្រូអ្នកគ្រូទាំងអស់បានបង្ហាញអំពីកិច្ចការងាររបស់ខ្លួនពរពេញដោយទំនួលខុសត្រូវខ្ពស់ ពិសេសបានបង្រៀនសិស្សានុសិស្សទាំងអស់រហូតដល់បំណាច់ឆ្នាំសិក្សា។ នាងខ្ញុំសូមគោរពជូនពរដល់លោកគ្រូអ្នកគ្រូឲ្យជួបតែសុខសុវត្ថិភាព ហើយរក្សាទំនាក់ទំនងល្អជាមួយសាលាបន្តទៅទៀត។

តារាងខាងក្រោមគឺជាព័ត៌មានសង្ខេបរបស់លោកគ្រូអ្នក គ្រូសម្រាប់ឆ្នាំសិក្សា២០១៨-២០១៩ ហើយនាងខ្ញុំមានភាពរីករាយដែលបានលោកគ្រូអ្នកគ្រូចូលរួមបង្រៀនជាមួយនឹងសាលាអន្តរជាតិ ISSR ។ ខ្ញុំជឿជាក់ថាលោកគ្រូ អ្នកគ្រូក៏រីករាយក្នុងការសហការល្អជាមួយសាលាផងដែរ

| ឈ្មោះថ្នាក់រៀន | ឈ្មោះថ្នាក់រៀន២០១៨-២០១៩ | ឈ្មោះគ្រូៗបន្ទុកថ្នាក់ |
|---|---|---|
| ថ្នាក់ Reception 1A | ថ្នាក់ Reception 2A | អ្នកគ្រូ Katie |
| ថ្នាក់ Reception 1B | ថ្នាក់ Reception 2B | អ្នកគ្រូ Chris |
| ថ្នាក់ Reception 2A | ថ្នាក់ទី 1A | អ្នកគ្រូ Triona |
| ថ្នាក់ Reception 2B | ថ្នាក់ទី 1B | អ្នកគ្រូ Belinda |
| ថ្នាក់ទី 1A | ថ្នាក់ទី 2A | អ្នកគ្រូ Hayley |
| ថ្នាក់ទី 1B | ថ្នាក់ទី 2B | លោកគ្រូ Philip |
| ថ្នាក់ទី 2A | ថ្នាក់ទី 3A | អ្នកគ្រូ Bernadette |
| ថ្នាក់ទី 2B | ថ្នាក់ទី 3B | អ្នកគ្រូ Gemma |
| ថ្នាក់ទី 3A | ថ្នាក់ទី 4A | លោកគ្រូ Patrick |
| ថ្នាក់ទី 3B | | |
| ថ្នាក់ទី 4A | ថ្នាក់ទី 5A | លោកគ្រូ Glen |
| ថ្នាក់ទី 4B | ថ្នាក់ទី 5B | លោកគ្រូ David |
| ថ្នាក់ទី 5A | ថ្នាក់ទី 6A | អ្នកគ្រូ Evelien |
| ថ្នាក់ទី 5B | ថ្នាក់ទី 6B | អ្នកគ្រូ Carrie |

ថ្ងៃបិទបបវេសនកាលសម្រាប់ឆ្នាំសិក្សា២០១៧-២០១៨ និងប្រព្រឹត្តទៅ
នៅថ្ងៃ**សុក្រ ទី២២ ខែមិថុនា** ឆ្នាំ២០១៨ វេលាម៉ោង៩:00 ព្រឹក
សាលានឹងឈប់សម្រាកបន្ទាប់ពីកម្មវិធីបិទបវេសនកាលចប់។

**មានតែអាហារដែលមានផាសុកភាពទេ ដែលអនុញ្ញាតឱ្យយកមកសាលារៀនសម្រាប់កូនៗទទួលទាន។**




## អំពីការចូលរួមនៅ Kingdom Fight Gym

កាលពីថ្ងៃអង្គារ ទី២២ និងថ្ងៃព្រហស្បត្តិ៍ ទី២៤ ខែឧសភាកន្លងទៅនេះសិស្សមួយចំនួនបានចូលរួមក្នុងការសាកល្បងគុនខ្មែរ នៅកីឡាដ្ឋាន Kingdom Fight Gym ដែលទើបនឹងបើកជាលើកដំបូងក្នុងទឹកដីខេត្តសៀមរាប។ សិស្សបានបង្ហាញអំពីទឹកចិត្តស្រលាញ់ ហើយសិក្សាអំពីគុនបុរាណខ្មែរ ព្រមទាំងមានការហាត់រៀនខ្លះៗពីសំណាក់ក្រុមគ្រូបង្វឹកនៅទីនោះ។



